**ក្រុមប្រឹក្សារដ្ឋ/រដ្ឋសភា**

**ក្រឹត្យ/ច្បាប់/១១ ក្រ/០៧ កុម្ភៈ ១៩៩២/ស្តីពី ការផ្តន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋាន ដោយខុសពីបទបញ្ជា**

## ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

ប្រកាសអោយប្រើច្បាប់ ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩២ នាសម័យប្រជុំសាមញ្ញលើកទី២២ នីតិកាលទី១។

ធ្វើនៅភ្នំពេញថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

## ច្បាប់

## ស្តីពី

## ការផ្តន្ទាទោសការកាន់អាវុធ និង

## ការពាក់សំលៀកបំពាក់ឯកសណ្ឋាន ដោយខុសពីបទបញ្ជា

**មាត្រា១:** ជនណាដែលគ្មានសិទ្ធិពាក់សំលៀកបំពាក់ឯកសណ្ឋានតាមបទបញ្ជាណាមួយ ហើយពាក់សំលៀកបំពាក់ឯកសណ្ឋាននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១ ខែ ដល់ ១ឆ្នាំ។

ជនណាដែលពាក់ស័ក្តិដែលខ្លួនគ្មានសិទ្ធិពាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ។

សំលៀកបំពាក់ឯកសណ្ឋានតាមបទបញ្ជាគឺ: សំលៀកបំពាក់សំរាប់អ្នកបួសក្នុងសាសនា និងសំលៀកបំពាក់សំរាប់អ្នករដ្ឋការ យោធិន នគរបាល ឬ ស៊ីវិលដែលមានកំណត់ក្នុងអត្ថបទជាធរមាន។

**មាត្រា២:** ជនណាដែលកាន់កាប់ លក់ ទិញ រក្សាទុកដោយគ្មានលិខិតអនុញ្ញាតត្រឹមត្រូវ នូវគ្រឿងផ្ទុះ គ្រាប់រំសេវ កាំភ្លើងគ្រប់ប្រភេទ លើកលែងតែកាំភ្លើងខ្យល់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ឆ្នាំ ដល់ ៥ឆ្នាំ។

**មាត្រា៣:** ជនណាដែលបានអោយ បានអោយខ្ចី ឬបានជូលកាំភ្លើង គ្រឿងផ្ទុះ ឬ គ្រាប់រំសេវដែលខ្លួនមានលិខិតកាន់កាប់ត្រឹមត្រូវ ទៅជនដែលគ្មានការអនុញ្ញាតតាមបទបញ្ជា ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ។

**មាត្រា៤:** ជនណាផលិតកាំភ្លើង គ្រឿងផ្ទុះ ឬ គ្រាប់រំសេវដូចមានចែងក្នុងមាត្រា ២ នៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ។

**មាត្រា៥:** វត្ថុតាងនៃបទល្មើសដែលមានចែងក្នុងមាត្រា ២ និង មាត្រា ៤ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

**មាត្រា៦:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជា អនុម័តនៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំ សាមញ្ញលើកទី ២២ នីតិកាលទី ១។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា

ជា ស៊ីម